

# ការប្រមូលទិន្នន័យរបស់អ្នកជំងឺថ្មី

## លើកក្រោយនៅពេលដែលអ្នកទៅមន្ទីរពេទ្យ អ្នកអាចនឹងឃើញ ឬត្រូវបានគេសួរសំណួរថ្មីៗអំពីជាតិសាសន៍ ជាតិពន្ធុ ភាសា និន្នាការផ្លូវភេទ យេនឌ័រ និងពិការភាព។

មន្ទីរពេទ្យនានាចែករំលែកព័ត៌មានអំពីការស្នាក់នៅរបស់អ្នកជំងឺ ជាមួយនឹង Washington State Department of Health (DOH, ក្រសួងសុខាភិបាល) នៃរដ្ឋវ៉ាស៊ីនតោន។ ឥឡូវនេះ ច្បាប់របស់រដ្ឋវ៉ាស៊ីនតោនតម្រូវឱ្យអ្នកផ្តល់សេវាថែទាំសុខភាពដែលជាមន្ទីរពេទ្យ សួរអ្នកជំងឺអំពីព័ត៌មានស្តីពីជាតិសាសន៍ ជាតិពន្ធុ ភាសា និន្នាការផ្លូវភេទ យេនឌ័រ និងពិការភាព។

DOH បានធ្វើការជាមួយសហគមន៍នានានៅរដ្ឋវ៉ាស៊ីនតោន នៅពេលធ្វើការបង្កើតប្រភេទថ្មីៗទាំងនេះ។ ព័ត៌មាននេះជួយឱ្យរដ្ឋយល់ដឹងថានរណាជាអ្នកប្រើប្រាស់សេវាមន្ទីរពេទ្យ និងដោយសារមូលហេតុអ្វី។ នៅពេលដែល DOH យល់អំពីរបៀបដែលសហគមន៍នានាប្រើប្រាស់មន្ទីរពេទ្យ នោះយើងអាចបម្រើសេវាជូនសហគមន៍បានកាន់តែពោរពេញដោយអត្ថន័យ។

## មូលហេតុដែលយើងសាកសួរ

ចម្លើយរបស់លោកអ្នកទៅនឹងសំណួរទាំងនេះជួយដល់ផ្នែកសុខភាពសាធារណៈ។ មន្ត្រីសុខភាពសាធារណៈចង់ដឹងថាតើនរណាជាអ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុតដោយសារវិសមភាពនៅក្នុងលទ្ធភាពទទួលបានការថែទាំសុខភាព គុណភាពនៃការថែទាំសុខភាព និងលទ្ធផលសុខភាព។ នៅពេលដែលយើងដឹងពីរបៀបដែលសហគមន៍នានាប្រើប្រាស់មន្ទីរពេទ្យ យើងអាចរៀបចំផែនការអំពីវិធីសាស្ត្រល្អបំផុតក្នុងការជួយដល់សហគមន៍នានា។ វិសមភាពនៃការថែទាំសុខភាពគឺមានភាពស្មុគស្មាញ។ នៅពេលដែលយើងយល់ដឹងកាន់តែច្បាស់ នោះយើងកាន់តែអាចមានភាពប្រសើរឡើង។

## អ្នកមានឱកាសក្នុងការសម្រេច

អ្នកចង់ឆ្លើយសំណួរទាំងនេះឬក៏អត់នោះគឺអាស្រ័យលើអ្នក។ ទោះបីជាមន្ទីរពេទ្យត្រូវតែសួរអ្នកនូវសំណួរទាំងនេះក៏ដោយ គឺអ្នកមិនត្រូវបានតម្រូវឱ្យត្រូវតែឆ្លើយសំណួរទាំងនោះទេ។ សម្រាប់សំណួរដែលអ្នកមិនចង់ឆ្លើយ អ្នកអាចជ្រើសរើសយក “Patient declined to respond (អ្នកជំងឺបានបដិសេធមិនឆ្លើយតប)”។ DOH សង្ឃឹមថាអ្នកនឹងឆ្លើយសំណួរទាំងអស់នេះ ដើម្បីឱ្យយើងអាចបម្រើសេវាជូនអ្នក និងពលរដ្ឋនៅវ៉ាស៊ីនតោនទាំងអស់បានកាន់តែប្រសើរ។

## តើអ្នកការពារឯកជនភាពរបស់ខ្ញុំដោយរបៀបណា?

យើងចង់ឱ្យគ្រប់គ្នាមានអារម្មណ៍ថាមានសុវត្ថិភាពក្នុងការឆ្លើយសំណួរទាំងនោះ។ ព័ត៌មានរបស់អ្នកគឺត្រូវបានរក្សាជាការសម្ងាត់ជាដាច់ខាត ហើយនឹងត្រូវបានចាត់ទុកថាជាកំណត់ត្រាសុខភាពសាធារណៈសម្ងាត់។ DOH មិនរួមបញ្ចូលព័ត៌មានផ្ទាល់ខ្លួនដូចជាឈ្មោះ ឬថ្ងៃខែឆ្នាំកំណើតនោះទេ នៅពេលរាយការណ៍ព័ត៌មាន។

ការចែករំលែកព័ត៌មានរបស់អ្នកជាមួយយើង នឹងមិនប៉ះពាល់ដល់អត្ថប្រយោជន៍ណាមួយដែលអ្នកទទួលបានពីរដ្ឋ ដូចជា Supplemental Nutrition Assistance Program (SNAP, កម្មវិធីជំនួយផ្នែកអាហារូបត្ថម្ភបន្ថែម) ឬ Apple Health នោះទេ។ ព័ត៌មាននេះនឹងមិនត្រូវបានចែករំលែកជាមួយមន្ត្រីអន្តោប្រវេសន៍នោះទេ។

Washington State Department of Health

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរស័ព្ទមកលេខ 1-800-525-0127។ អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរស័ព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

DOH 422-237 December 2022 Khmer